ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ៣៦/១០-សៅធ៍បាយ និង ហ្គោលដេនក្រោន

កាលបរិច្ឆេទនៃសេចក្ដីសម្រេច : ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១០

# សេចក្ដីសម្រេចអាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក: យូ សុនទី

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: លីវ សុវណ្ណា

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ: អាំង អេងថុង

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន សៅធ៍បាយ អ៊ិនធើព្រាយស៍ កូ អិលធីឌី និង ហ្គោលដេន ក្រោន (ខេមបូឌា)

អាសយដ្ឋាន : ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្ដាល

ទូរស័ព្ទ : ០១២ ៣៨៥ ៧០៥ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ :

១- លោក Ni Yi ប្រធានរដ្ឋបាល

២- លោកស្រី ជា សុវណ្ណច័ន្ទសម្បត្តិ ជំនួយការរដ្ឋបាល

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ :

១- លោកស្រី Guo Hai Jing ប្រធានរដ្ឋបាល

២- លោកស្រី ជា សុវណ្ណច័ន្ទសម្បត្តិ ជំនួយការរដ្ឋបាល

៣- លោក ឡុង ហ៊ាង មន្ត្រីសមាគមរោងចក្រកាត់ដេរកម្ពុជា

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សហព័ន្ធសហជីពកម្មករកម្ពុជា

- សហជីពកម្មករនិយោជិតរោងចក្រ សោធទ័បេរ

- សហជីពកម្មករនិយោជិតរោងចក្រ ហ្គោលឌិន គ្រោន

អាសយដ្ឋាន : (បូរីសឡា ) ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១៧ ៦១៦ ៥៩៨ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ និងទី២ :

| | |
|---|---|
| ១- លោក ហ៊ូរ ពៅ | មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា |
| ២- លោក យ៉ង់ សុខ | ប្រធានសហជីពកម្មករនិយោជិតរោងចក្រ សោធទ័បេរ |
| ៣- លោក ឃឹម សរ | អនុប្រធានសហជីពកម្មករនិយោជិតរោងចក្រ សោធទ័បេរ |
| ៤- លោក យ៉ាង យាន់ | លេខាធិការសហជីព ប្រចាំរោងចក្រ សោធទ័បេរ |
| ៥- លោក ម៉ៅ សារឿន | ទីប្រឹក្សាសហជីព ប្រចាំរោងចក្រ សោធទ័បេរ |
| ៦- លោក ភឿង សារុធ | ប្រធានសហជីពកម្មករនិយោជិតរោងចក្រ ហ្គោលឌិនគ្រោន |
| ៧- លោក អាន សារឿន | អនុប្រធានសហជីព ប្រចាំរោងចក្រ ហ្គោលឌិន គ្រោន |
| ៨- កញ្ញា ទ្រា សុខឃីម | លេខាធិការសហជីព ប្រចាំរោងចក្រ ហ្គោលឌិន គ្រោន |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ក្រុមហ៊ុនឯកភាពថែមប្រាក់រង្វាន់ការងារទៀងទាត់រហូតដល់ ១៣ ដុល្លារ (ដប់បីដុល្លារ ) ក្នុងមួយខែ នៅពេលក្រុមហ៊ុនចាប់ផ្តើមដំណើរការការងារឡើងវិញ ។ ចំពោះប្រាក់ឧបត្ថម្ភការងារ ក្រុមហ៊ុនមានលទ្ធភាពផ្តល់ជូនតែ ៧ ដុល្លារ (ប្រាំពីរដុល្លារ) ប៉ុណ្ណោះ ក្នុងមួយខែ ។

- ភាគីកម្មករមិនឯកភាពចំពោះប្រាក់ថ្លៃឧបត្ថម្ភការងារ ៧ ដុល្លារ ( ប្រាំពីរដុល្លារ ) ក្នុងមួយខែ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជា

ឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១៨៣/១០ កប/កណ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល " ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យគន្ធទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** - លើកទី១ : ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។
- លើកទី២ : ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពកម្មករកម្ពុជា ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារបានចាត់តាំងមន្ត្រីជំនាញ ដើម្បីធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងផ្សះផ្សាចុងក្រោយ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ ។ ប៉ុន្តែជាលទ្ធផល ទាក់ទងទៅនឹងការផ្សះផ្សានេះ ពុំមានចំណុចណាមួយទទួលបានលទ្ធផលសះជានឹងគ្នាទេ ។ ចំណុចវិវាទដែលមិនសះជានឹងគ្នាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ តាមរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១៨៣/១០ កប/កណ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០ វេលាម៉ោង ១៤:០០ នាទី រសៀល ។ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលព្យាយាមសួររកនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ ហើយបានធ្វើការផ្សះផ្សាបន្ថែមទៀត ប៉ុន្តែដោយសារទាក់ទងទៅនឹងការសម្រេចចិត្ត ភាគីនិយោជកចាំបាច់ត្រូវមានការឆ្លងកាត់ពីនាយកក្រុមហ៊ុន ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទុកពេលវេលាជូនភាគី ដើម្បីធ្វើការពិចារណា ហើយក៏បានធ្វើការកំណត់សវនាការលើកទី២ បន្តទៀត ។

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០ តាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកចូលរួមសវនាការជាលើកទី២។ នៅក្នុងសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការសាកសួរជុំវិញបញ្ហាចំណុចវិវាទ ហើយបានផ្សះផ្សាលើចំណុចមិនសះជានេះបន្ថែមទៀត ប៉ុន្តែជាលទ្ធផល ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ មិនទទួលបានការសះជានឹងគ្នាទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណា និងដោះស្រាយដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតរបស់ប្រធាននាយកដ្ឋានអធិការកិច្ចការងារលេខ ៧១៩ កប/អក/អធក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ជម្រាបមកលោកនាយកក្រុមហ៊ុន ហ្គោលដេនក្រោន (ខេមបូឌា) ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ។

២- លិខិតរបស់ប្រធាននាយកដ្ឋានអធិការកិច្ចការងារលេខ ៧៣៨ កប/អក/អធក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ជម្រាបមកលោកនាយកក្រុមហ៊ុន សៅធ៍បាយ អ៊ិនធើប្រាយ កូអិលធីឌី ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ។

៣- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ហ្គោដេនក្រោន ជូនលោកស្រី Guo Hai Jing ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០ ។

៤- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន សោធ៍បាយ ជូនលោកស្រី Guo Hai Jing ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជីកាសហជីពកម្មករនិយោជិតរោងចក្រ សោធប៊ែរ លេខ ១៤២០ កប/វក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៨ ។

២- វិញ្ញាបនប័ត្រចុះបញ្ជីកាសហជីពកម្មករនិយោជិតរោងចក្រ ហ្គោឌិនក្រោន លេខ ១៤៤១ កប/វក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ ។

៣- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត សហជីពកម្មករនិយោជិតរោងចក្រ សោធប៊ែរ លេខ ០៦៥/០៨ ក.ប ចុះ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨ ។

៤- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត សហជីពកម្មករនិយោជិតរោងចក្រ ហ្គោឌិនគ្រោន លេខ ០៦២/០៨ ក.ប ចុះ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្គោដេនគ្រោន និងសៅធីបាយ លេខ ១៨៣/១០ កប/កណ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ហ្គោដេនគ្រោន និងសៅធីបាយ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៨៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែ មេសា ឆ្នាំ២០១០ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៨៧ កប/អក/វក/លកអ. ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១០ ។

**អនុលោមតាម**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន សៅធីបាយ និង ហ្គោលដេនគ្រោន គឺជានិយោជកតែមួយនៅក្នុងសំណុំរឿងនេះ។ ក្រុមហ៊ុន សៅធីបាយ បានចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ១៩៩៧ ចំណែកឯក្រុមហ៊ុន ហ្គោលដេន គ្រោន វិញ បានចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ២០០៤ ។ នៅក្នុងក្រុមហ៊ុនទាំងពីរនេះ មានជួលកម្មករនិយោជិត សរុបចំនួនប្រហែល ១៤០០ នាក់។ ក្រុមហ៊ុននេះ មានសហជីពតែមួយគត់ គឺសហជីពកម្មករ និយោជិតប្រចាំរោងចក្រ សៅធីបាយ និង ហ្គោលដេន គ្រោន ។
- សហជីពកម្មករនិយោជិតប្រចាំរោងចក្រ សៅធីបាយ និង ហ្គោលដេន គ្រោន គឺជាដើមបណ្តឹងនៅក្នុង សំណុំរឿងនេះ។ សហជីពកម្មករនិយោជិត មានភាពជាតំណាងបំផុត នៅក្នុងក្រុមហ៊ុន សៅធីបាយ និងក្រុមហ៊ុន ហ្គោលដេន គ្រោន ។

ចំណុចវិវាទ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន គិតប្រាក់ឈ្នួលគោល ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ពេញ ១០០ ភាគរយ ពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ

- នៅក្នុងសវនាការ ភាគីកម្មករនិយោជិត បានបញ្ជាក់ពីការទាមទាររបស់ខ្លួនថា ពួកគាត់ទាមទារសុំឱ្យនិយោជក គិតប្រាក់ឈ្នួលគោលពេញ ប្រាក់ទ្រទ្រង់ជីវភាពចំនួន ៦ ដុល្លារអាមេរិក ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក និងប្រាក់អតីតភាពការងារទៅតាមចំនួនឆ្នាំ ដែលកម្មករនិយោជិតមានកំឡុងពេលដែលនិយោជក ធ្វើការព្យួរការងារ ដោយពុំមានការអនុញ្ញាតត្រឹមត្រូវពីអធិការការងារ ។
- ភាគីនិយោជកបានលើកឡើងថា ដោយសារពុំមានតម្រូវការពីអ្នកបញ្ជាទិញ និងមានការផ្លាស់ប្តូរទីតាំងរោងចក្រ ក្រុមហ៊ុនបានធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួនប្រហែល ១៣០០ នាក់ ដោយក្រុមហ៊ុនបានធ្វើការព្យួរ ចាប់ពីថ្ងៃទី០១ ខែមករា ទៅដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១០។ ក្រុមហ៊ុនបានព្យួរកិច្ចសន្យាការងារនេះ ចំពោះកម្មករនិយោជិតទូទៅ តែលើកលែងចំពោះប្រធានក្រុម និងថ្នាក់ដឹកនាំសហជីព និងកម្មករផ្នែកឃ្លាំង (កម្មករផ្នែកឃ្លាំងមានចំនួនប្រហែល ៥០ ភាគរយ) ប៉ុណ្ណោះ ដែលនិយោជកពុំបានធ្វើការព្យួរការងារ។ ភាគីកម្មករនិយោជិតមិនបានជំទាស់ទៅនឹងការលើកឡើងនេះទេ ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា ការព្យួរកិច្ចសន្យាការងារនេះ និយោជកពុំមានលិខិតអនុញ្ញាតពីអធិការការងារទេ ហើយទាក់ទងទៅនឹងការព្យួរនេះ និយោជកបានផ្តល់ជូនកម្មករនិយោជិតចំនួនតែ ៧ ដុល្លារអាមេរិកប៉ុណ្ណោះ ក្នុងរយៈពេលមួយខែ។
- ភាគីកម្មករនិយោជិត និងនិយោជកបានឯកភាពគ្នាថា កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលគោលជាមធ្យមចំនួនពី ៥៥ ដុល្លារអាមេរិក ទៅ ៧០ ដុល្លារអាមេរិក ក្នុងមួយខែ ហើយក្រៅពីប្រាក់ឈ្នួលគោល និយោជកបានផ្តល់អត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត ដូចជា ប្រាក់ទ្រទ្រង់ជីវភាពចំនួន ៦ ដុល្លារអាមេរិក ប្រាក់អតីតភាពការងារ និងប្រាក់រង្វាន់ធ្វើការងារទៀងទាត់។ ចំពោះប្រាក់រង្វាន់ធ្វើការងារទៀងទាត់ គឺក្រុមហ៊ុនបានផ្តល់ជូនដល់កម្មករនិយោជិតចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតដែលមកធ្វើការងារទៀងទាត់ ហើយក្រុមហ៊ុនបានគំរោងផ្តល់ជូនចំនួន ០៣ ដុល្លារអាមេរិក បន្ថែមទៀត ដើម្បីលើកទឹកចិត្តដល់កម្មករនិយោជិតទាំងអស់ដែលក្រុមហ៊ុនពុំមានការងារឱ្យកម្មករនិយោជិតធ្វើកន្លងមក ។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេចៈ**

**ចំណុចវិវាទ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន គិតប្រាក់ឈ្នួលគោល ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ពេញ ១០០ ភាគរយ ពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ**

ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកគិតប្រាក់ឈ្នួល ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ជូនក្នុងកំឡុងពេលដែលនិយោជកបានព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាទៅលើការទាមទាររបស់កម្មករនិយោជិត ដូចខាងក្រោម :

មាត្រា ៧១ កថាខណ្ឌទី១១ នៃច្បាប់ស្តីពីការងារបានចែងថា *"ពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសំភារៈធូន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពសហគ្រាស មិនលើសពីពីរខែ ។ ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការកិច្ចការងារ ។"*

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការបកស្រាយមាត្រាខាងលើនេះថា ជាទូទៅ ទាក់ទងនឹងការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនត្រូវមានការជូនដំណឹងទៅអធិការកិច្ចការងារ និងមានការពិនិត្យ និងបញ្ជាក់ពីអធិការកិច្ចការងារជុំវិញបញ្ហាព្យួរកិច្ចសន្យាការងារនេះ ។ មានន័យថា អធិការកិច្ចការងារត្រូវផ្តល់លិខិតឆ្លើយតបនឹងការស្នើសុំព្យួរសកម្មភាពការងាររបស់ក្រុមហ៊ុនថា ពិតជាអនុលោមទៅតាមភាពជាក់ស្តែងនៃស្ថានភាពលំបាកផ្នែកសេដ្ឋកិច្ចពិតប្រាកដមែន ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥១/០៩-យ៉ុង វ៉ា ទី១ និងទី២ និង លេខ ៩៥/០៩-តាក ហ្វាត ចំណុចវិវាទទី១០ ) ។*

មាត្រា ៧២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារបានចែងថា" *ការព្យួរកិច្ចសន្យាការងារនាំអោយប៉ះពាល់ចំពោះតែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យ និយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត ។..."*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ច្បាប់ស្តីពីការងារបានផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការព្យួរកិច្ចសន្យាការងារ ហើយប្រសិនបើក្រុមហ៊ុនបានធ្វើបែបបទព្យួរការងារតាមនីតិវិធីច្បាប់ស្តីពីការងារត្រឹមត្រូវដោយមានការអនុញ្ញាតពីអធិការកិច្ចការងារហើយនោះ ក្រុមហ៊ុនមិនមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតឡើយ *(សូមមើលមាត្រា ៧២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារ)* ។ ប៉ុន្តែ ប្រសិនបើ ក្រុមហ៊ុនមិនបានគោរពតាមច្បាប់ស្តីពីការងារនៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ដូចបានរៀបរាប់ខាងលើទេនោះ ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ដល់កម្មករនិយោជិត ទោះបីជាពុំមានការងារឱ្យកម្មករនិយោជិតធ្វើក៏ដោយ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៣/០៨-យុង វ៉ា ទី១ ចំណុចវិវាទទី១, លេខ ៤២/០៩-វីវីរីច តិចស្តាយ ចំណុចវិវាទទី៤ និងលេខ ១២៣/០៩-ស៊ូត វ៉ េ ចំណុចវិវាទទី២ )* ។

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏យល់ឃើញដូចក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរថា គឺក្រុមហ៊ុនត្រូវមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលគោល ១០០ ភាគរយ និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិត នៅពេលដែលក្រុមហ៊ុនធ្វើការព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ស្តីពីការងារ ។

តាមរយៈអង្គហេតុ និយោជកបានធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួនប្រហែលជា ១៣០០ នាក់ ដែលចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ទៅដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១០ ហើយបានផ្តល់ប្រាក់ចំនួន ៧ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតម្នាក់ៗ ។ ក្នុងករណីការព្យួរកិច្ចសន្យាការងារនេះ និយោជកពុំបានទទួលការអនុញ្ញាតពីអធិការការងារទេ ដូចនេះ យោងតាមមាត្រា ៧១ នៃច្បាប់ស្តីពីការងារ និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ យល់ឃើញថា និយោជកត្រូវមានកាតព្វកិច្ចក្នុងការផ្តល់ប្រាក់ឈ្នួលពេញ ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិត ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងាររយៈពេល ៣ ខែ ១៨ ថ្ងៃនេះ ។

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ទាក់ទងទៅនឹងអត្ថប្រយោជន៍ផ្សេងៗ ដែលនិយោជកត្រូវផ្តល់ជូននោះមាន ដូចជា ប្រាក់ទ្រទ្រង់ជីវភាពចំនួន ៦ ដុល្លារអាមេរិក ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក និងប្រាក់អតីតភាពការងារទៅតាមចំនួនឆ្នាំ ដែលកម្មករនិយោជិតមាន ។ ដូចនេះ និយោជកត្រូវផ្តល់ប្រាក់ឈ្នួលគោលពេញ និងអត្ថប្រយោជន៍ផ្សេងៗ មានដូចជាប្រាក់ទ្រទ្រង់ជីវភាពចំនួន ៦ ដុល្លារអាមេរិក ប្រាក់រង្វាន់ធ្វើការងារទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក និងប្រាក់អតីតភាពការងារទៅតាមចំនួនឆ្នាំ ដែលកម្មករនិយោជិតមាន នៅពេលក្រុមហ៊ុនធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតមិនស្របទៅតាមនីតិវិធីច្បាប់ ។

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

ចំណុចវិវាទ : បង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលគោលពេញ និងអត្ថប្រយោជន៍ផ្សេងៗ មានដូចជា ប្រាក់ទ្រទ្រង់ជីវភាពចំនួន ៦ ដុល្លារអាមេរិក ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក និងប្រាក់អតីតភាពការងារទៅតាមចំនួនឆ្នាំ ដែលកម្មករនិយោជិតមាន នៅពេលក្រុមហ៊ុនធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ចាប់ពីថ្ងៃទី០១ ខែមករា ទៅដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០១០ ។

THE ARBITRATION COUNCIL

**ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : យូ សុនទី

ហត្ថលេខា: ------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : លីម សុវណ្ណា

ហត្ថលេខា: ------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : អ៊ឹង ម៉េងថុង

ហត្ថលេខា: ------------------------

THE ARBITRATION COUNCIL